CITY of LOWELL

# ការណែនាំសម្រាប់អាជីវកម្ម

ចង់បើកអាជីវកម្មនៅទីក្រុងឡូវែល? នេះជាទិដ្ឋភាពរួមនៃដំណើការ និងលក្ខខណ្ឌច្បាប់ទូទៅ។ សម្រាប់ព័ត៌មានទំនាក់ទំនងអំពីការណែនាំជាក់លាក់ណាមួយ សូមទាក់ទងនាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច តាមរយៈ DoBizInLowell@lowellma.gov ឬ 978-674-1437។

## 01 បង្កើតអាជីវកម្ម

ទិដ្ឋភាពទូទៅនៃលិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណនៅក្រុងឡូវែល

## 02 លិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណ

បញ្ជីលិខិតអនុញ្ញាត អាជ្ញាប័ណ្ណ និងកិច្ចសន្យា

## 03 ទីតាំងអាជីវកម្មក្នុងក្រុងឡូវែល

សង្កាត់អាជីវកម្មក្នុងមូលដ្ឋាន ដែលមានសកម្មភាពរស់រវើក

## 04 ហេតុអ្វីទីក្រុងឡូវែល?

មូលហេតុដែលបើកអាជីវកម្មអ្នកនៅទីនេះ

## 05 ធនធានសម្រាប់អាជីវកម្មខ្នាតតូច

បង្រៀនធ្វើអាជីវកម្ម ឲ្យប្រាក់ខ្ចី និងធនធានសម្រាប់អាជីវកម្មអ្នក

* មានអាជីវកម្មខ្លះ គ្រប់គ្រងដោយច្បាប់រដ្ឋម៉ាសាឈូសេត មិនឋិតក្រោមការគ្រប់គ្រងនៃច្បាប់របស់ទីក្រុងឡូវែលនោះឡើយ។ អាជីវកម្មទាំងនេះ រួមមានពាណិជ្ជកម្ម មណ្ឌលសុខភាព កន្លែងមើលក្មេង និងផ្សេងៗទៀត។ បើអ្នកមិនដឹងថាអ្នកត្រូវការអាជ្ញាប័ណ្ណពីរដ្ឋ ឬក្រុង ខាងគណៈកម្មការអាជ្ញាប័ណ្ណ អាចឆ្លើយសំណួរអ្នកបាន តាមលេខ (978-674-4156)*

# 01 បង្កើតអាជីវកម្មរបស់អ្នក

នេះជាទិដ្ឋភាពរួម នៃលិខិតអនុញ្ញាត និងការសុំអាជ្ញាប័ណ្ណ ក្នុងក្រុងឡូវែល។ មិនមែនរាល់ទិដ្ឋភាពទាំងនេះ សុទ្ធតែត្រូវនឹងអាជីវកម្មរបស់អ្នកនឡើយ។ សម្រាប់ការណែនាំជាក់លាក់ សូមទាក់ទងនាយដ្ឋានសេដ្ឋកិច្ចតាម DoBizInLowell@lowellma.gov ឬ 978-674-1437។

## 1 រៀបចំផែនការអាជីវកម្ម

មានផែនការអាជីវកម្មច្បាស់លាស់ និងលម្អិតមួយ គឺជាជំហានដំបូង សម្រាប់ឈានទៅរកភាពជោគជ័យ។ ធនធានសម្រាប់ជួយផ្នែកអាជីវកម្មនេះ មាននៅទីក្រុងឡូវែល សម្រាប់អ្នកប្រើប្រាស់ ក្នុងការរៀបចំផែនការអាជីវកម្ម។

## 2 រកមើលទីតាំង

ប្រើសេវារកទីតាំងរបស់សាលាក្រុង ដើម្បីរកមើលទីកន្លែងណាមួយ ដែលត្រូវនឹងសេចក្តីត្រូវការរបស់អ្នក។ ទាក់ទងសេវាអភិវឌ្ឍន៍របស់ក្រុង ដើម្បីឲ្យច្បាស់ថា ទីតាំងដែលអ្នកត្រូវការនោះ គឺអាចប្រើប្រាស់បានតាមក្តីប្រាថ្នា និងឯកសារជួល។

## 3 ដាក់ពាក្យសុំលិខិតអនុញ្ញាតគ្រប់យ៉ាង និងអាជ្ញាប័ណ្ណ

លិខិតអនុញ្ញាត គឺបើកឲ្យធ្វើជាក់លាក់មួយ ដូចជាការជួលជុលកែលម្អអគារ។ ចំណែកអាជ្ញាប័ណ្ណ គឺផ្តល់សិទ្ធិអនុញ្ញាតទូទៅឲ្យបើកអាជីវកម្មទូទៅណាមួយ។  រាល់ម្ចាស់អាជីវកម្មឯកបុគ្គលនឹង ត្រូវការលិខិតបញ្ជាក់អាជីវកម្ម ត្រូវដាក់ពាក្យទៅស្មៀនក្រុង។ លិខិតបញ្ជាក់អំពីការស្នាក់នៅ និងលិខិតអនុញ្ញាតលើកស្លាកពីសេវាអភិវឌ្ឍន៍។ សេចក្តីត្រូវការខ្លះផ្នែកអាជីវកម្ម លិខិតអនុញ្ញាតបន្ថែម គឺអាស្រ័យលើសកម្មភាពអាជីវកម្ម។ ការជួលជុលកែលម្អ លក់ចំណីអាហារ ឬស្រា  លើកស្លាក និងស្ថានភាពផ្សេងៗឯទៀត គឺតម្រូវឲ្យមានលិខិតអនុញ្ញាតបន្ថែម និងអាជ្ញាប័ណ្ណ ដើម្បីឲ្យត្រូវច្បាប់របស់ក្រុង។

## 4 ប្រើប្រាស់ធនធានអាជីវកម្មក្រុងឡូវែល

ឡូវែលមានបណ្តាញធនធាន ដែលភាគច្រើនឥតគិតប្រាក់ ដើម្បីជួយដល់សហគ្រិន និងក្រុមហ៊ុនក្នុងទីក្រុងនេះ។ ក្រុមការងារដូចជា នាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចក្រុង មជ្ឈមណ្ឌល CTI's E-Center និងសភាពាណិជ្ជកម្ម គឺសុទ្ធតែប្តេជ្ញាក្នុងការជួយអាជីវកម្មមូលដ្ឋាន ឲ្យបើកដំណើរការ និងរីកចម្រើន។

*មានអាជីវកម្មខ្លះ គ្រប់គ្រងដោយច្បាប់រដ្ឋម៉ាសាឈូសេត មិនឋិតក្រោមការគ្រប់គ្រងនៃច្បាប់របស់ទីក្រុងឡូវែលនោះឡើយ។ អាជីវកម្មទាំងនេះ រួមមានពាណិជ្ជកម្ម មណ្ឌលសុខភាព កន្លែងមើលក្មេង និងផ្សេងៗទៀត។ បើអ្នកមិនដឹងថាអ្នកត្រូវការអាជ្ញាប័ណ្ណពីរដ្ឋ ឬក្រុង ខាងគណៈកម្មការអាជ្ញាប័ណ្ណ អាចឆ្លើយសំណួរអ្នកបាន តាមលេខ (978-674-4156)*

# 02 លិខិតអនុញ្ញាត និងអាជ្ញាប័ណ្ណ

| អាជីវកម្មរបស់ខ្ញុំ**ត្រូវការ...** | លិខិតអនុញ្ញាត/អាជ្ញាប័ណ្ណដែល | លេខទាក់ទង |
|---|---|---|
| បើកក្រុមហ៊ុនចូលគ្នា | ដាក់ពាក្យសុំនៅរដ្ឋម៉ាសាឈូសេត | លេខារដ្ឋម៉ាសាឈូសេត (online) |
| បើកជាលក្ខណៈឯកបុគ្គល | លិខិតបញ្ជាក់អាជីវកម្ម | ស្មៀនក្រុង<br>978-674-4161 |
| បញ្ជាក់ថាអគារមានសុវត្ថិភាព ក្រោយការជួលជុលកែលម្អ | លិខិតបញ្ជាក់សម្រាប់ចូលប្រើប្រាស់អគារ | សេវាអភិវឌ្ឍន៍<br>978-674-4144 |
| លើកស្លាក | លិខិតអនុញ្ញាតលើកស្លាក | |
| កែ ជួសជុល ឬវាយអគារចោល | លិខិតអនុញ្ញាតអគារ | |
| បំពេញតាមលក្ខខណ្ឌតម្រូវអប្បបរមា | លិខិតបញ្ជាក់អធិការកិច្ច | |
| ការងារពាក់ព័ន្ធនឹងហ្គាស គ្រឿងមេកានិច ប្រព័ន្ធទឹក ឬភ្លើង | លិខិតបញ្ជាក់ផ្សេងទៀតសម្រាប់អគារ | |
| សម្រាប់បញ្ជីលិខិតអនុញ្ញាតអគារ ពិនិត្យមើលបញ្ជីសេវាអភិវឌ្ឍ | | |
| លក់ចំណីអាហារ | របាយការណ៍អធិការកិច្ចចំណីអាហារ | សេវាអភិវឌ្ឍន៍<br>978-674-4144 |
| | លិខិតអនុញ្ញាតឲ្យលក់ចំណីអាហារ | |
| | ធានារ៉ាប់រងពេលមានគ្រោះថ្នាក់ | |
| | សំណងកម្មករ | |
| | លិខិតបញ្ជាក់ថាចេះសង្គ្រោះមនុស្សខក់ | |
| | ពាក្យសុំធុងដាក់សំរាម | |
| | លិខិតបញ្ជាក់ថាដឹងអំពីប្រតិកម្មអាហារ | |
| | ServSafe | |
| | ផែនការគ្រប់គ្រងសត្វល្អិត | |
| បម្រើស្រា | អាជ្ញាប័ណ្ណលក់រាយគ្រឿងស្រវឹង | គណៈកម្មការអាជ្ញាប័ណ្ណ<br>978-674-4156 |
| ខាងអាជីកម្មចំណីអាហារ សូមអានកញ្ចប់សម្រាប់ហាងថ្មី សម្រាប់បញ្ជីលិខិតអនុញ្ញាតដែលអាចត្រូវការ។ រថយន្តលក់ចំណីអាហារត្រូវការ**លិខិតអនុញ្ញាតបន្ថែម។** | | |
| កែអគារក្នុងសង្កាត់ប្រវត្តិសាស្ត្រ | លិខិតអនុញ្ញាតផ្នែកប្រវត្តិសាស្ត្រ | ក្រុមប្រឹក្សាប្រវត្តិសាស្ត្រ<br>978-674-1443 |
| បើកដំណើរការតាមចិញ្ចើមផ្លូវ ឬយកកន្លែងចតចម្រាប់បម្រើអាហារ | លិខិតអនុញ្ញាតសម្រាប់លក់ដូរក្រៅហាង និងភោជនីយដ្ឋាន | សេវាអភិវឌ្ឍន៍<br>978-674-4144 |
| បើកហាងបញ្ចាំ ឬលក់រាយ | អាជ្ញាប័ណ្ណលក់របស់ជជុះ | គណៈកម្មការអាជ្ញាប័ណ្ណ<br>978-674-4156 |
| ទិញ និងលក់រថយន្តជជុះ | អាជ្ញាប័ណ្ណលក់យានយន្តជជុះ | |

អាជីវកម្មជាច្រើនត្រូវការអាជ្ញាប័ណ្ណពាក់ព័ន្ធនឹងឧស្សាហកម្មបន្ថែម។ សូមទាក់ទងសេវាអភិវឌ្ឍន៍ ដើម្បីឲ្យច្បាស់ថាអ្នកមាន**អាជ្ញាប័ណ្ណគ្រប់សព្វទៅតាមសេចក្តីត្រូវការ។**

# 03 ទីតាំងអាជីវកម្មក្នុងទីក្រុងឡូវែល

ឡូវែលមានសង្កាត់អាជីវកម្មជាច្រើន ដែលប្រមូលផ្តុំទៅដោយសកម្មភាពពាណិជ្ជកម្ម។

1. ប្រជុំជនកណ្តាលក្រុង/Acre
2. Aiken Street
3. Bridge Street
4. Back Central
5. ក្រុងខ្មែរ
6. Cupples Square
7. Mammoth Rd.
8. University Ave.




## ឧបករណ៍រកទីតាំង

សូមប្រើសេវារកទីតាំងរបស់សាលាក្រុងឡូវែល ដើម្បីរកមើលអចលនទ្រព្យដែលត្រឹមត្រូវតាមក្រឹត្យក្រម។ បុគ្គលិករបស់យើងអាចជួយអ្នក ដើម្បីរកទីកន្លែងដែលសមស្រប ក្នុងក្រុងឡូវែល ទៅតាមទំហំ ទីតាំង និងលក្ខណៈពិសេសៗផ្សេងទៀត។ បើអ្នកត្រូវការជំនួយពីយើងខ្ញុំ ដើម្បីរកទីតាំងណាមួយ សូមដាក់សំណើតាមគេហទំព័រ។ យើងខ្ញុំនឹងឆ្លើយតបទៅអ្នក ឲ្យបានឆាប់ដែលអាចធ្វើទៅបាន។

## ការកំណត់តំបន់

តំបន់សម្រាប់ប្រើប្រាស់ជាកន្លែងអាជីវកម្ម ត្រូវបានកម្រិតអាស្រ័យលើទីតាំងនៅក្នុងតំបន់ទីក្រុងឡូវែល។ កន្លែងខ្លះច្បាប់អនុញ្ញាតឲ្យបើកអាជីវកម្ម គឺទាល់តែ“ត្រឹមត្រូវតាមក្រឹត្យក្រម”។ ឯកន្លែងខ្លះទៀត គឺតម្រូវឲ្យមានលិខិតអនុញ្ញាតពិសេសទើបបើកបាន។ កន្លែងអនុញ្ញាតឲ្យប្រើប្រាស់សម្រាប់អាជីវកម្ម មានពន្យល់លម្អិត នៅក្នុងសៀវភៅអំពីការកំណត់តំបន់។ សម្រាប់សំណួរអំពីកន្លែងប្រើប្រាស់សម្រាប់អាជីវកម្មនៅទីតាំងជាក់លាក់ណាមួយ ខាងសេវាអភិវឌ្ឍន៍អាចឆ្លើយបានតាម (978-674-4144)។

# 04 ហេតុអ្វីទីក្រុងឡូវែល?

## ការរីកចម្រើន និងទីក្រុងដែលមានចម្រុះជាតិសាសន៍ ជួយលើកតម្កើងសិល្បៈ និងវប្បធម៌៖

ទីក្រុងឡូវែល មានមោទនភាពយ៉ាងក្រៃលែង ដោយសារប្រវត្តិសាស្ត្រ សោភ័ណភាពដ៏អស្ចារ្យ សហគមន៍ចម្រុះ និងភូមិឋានល្អ ធនធានវប្បធម៌ និងសិល្បៈ។ ក្រុងឡូវែលកំពុងរីកលូតលាស់។ ពីឆ្នាំ ២០០០ ដល់ ២០២០ ចំនួនប្រជាពលរដ្ឋនៃក្រុងនេះ បានកើនជិត ៦ ភាគរយ គឺកើនពី ១០៥,០០០ នាក់ ដល់ ១១៥,០០០ នាក់។ កំណើនពលរដ្ឋនេះ គឺកើនស្របគ្នានឹងភាពចម្រុះនៃពូជសាសន៍ និងភាសាផងដែរ។

## ប្រព័ន្ធអេកូឡូស៊ីដ៏សម្បូរបែប នៃជើងឯកតស៊ូមតិក្នុងស្ថាប័ន និងអាជីវកម្មដែលជាម្ចាស់កម្មសិទ្ធិរបស់អ្នកមូលដ្ឋាន៖

ទីក្រុងឡូវែល ជាលំនៅឋាននៃស្ថានប័នជើងឯកនានា ដូចជាសកលវិទ្យាល័យ UMass Lowell, មន្ទីរពេទ្យធំក្រុងឡូវែល (Lowell General Hospital), និងផ្សារទំនើប Market Basket។ ម្ចាស់ស្ថាប័នទាំងនេះ និងអាជីវកម្មខ្នាតតូចរបស់យើងរាប់ពាន់ទៀត គឺកន្លែងផ្តល់ការងារធ្វើ, កន្លែងច្នៃប្រឌិត, និងកន្លែងលូតលាស់សេដ្ឋកិច្ចជាទូទៅ។ ឧទ្យានប្រវត្តិសាស្ត្រជាតិក្រុងឡូវែល, ពិធីបុណ្យ Lowell Folk Festival ជារៀងរាល់ឆ្នាំ និងបណ្តាញអង្គការមិនរកប្រាក់កម្រៃ និងកន្លែងវប្បធម៌ សុទ្ធតែជាផ្នែកក្នុងការធ្វើឲ្យទីក្រុងនេះ ជាទីដែលមានទំនាក់ទំនងគ្នាល្អ និងរស់រវើក។

## តំបន់ទីប្រជុំជនកណ្តាលទីក្រុងកំពុងតែលូតលាស់!

### ជំរឿនតំបន់ទីប្រជុំជនកណ្តាលក្រុង

| |
|---|
| ចំនួនគ្រួសារ ឆ្នាំ ២០២០<br>3,073 (ឡើង 37% ពី 2010) |
| មធ្យោបាយចំណូលគ្រួសារ ឆ្នាំ ២០២០<br>$77,252 (ឡើង 66% ឡើង 2010) |
| ចំណូលមធ្យមប្រចាំគ្រួសារ ឆ្នាំ២០២០<br>$54,176 (ឡើង 68% ឡើង 2010) |

ចំនួនស្មានពលរដ្ឋក្នុងពេលថ្ងៃរាប់ពីកម្មករ និងភ្ញៀវ៖ 13,000




### ពន្ធពន្យារពេលសងនិយោជកធំៗ

| | | |
|---|---|---|
| 1 | UMass Lowell | 4,944 |
| 2 | Lowell General | 3,650 |
| 3 | City of Lowell | 1,500 |
| 4 | Middlesex CC | 759 |
| 5 | CTI | 587 |
| 6 | LCHC | 538 |
| 7 | Enterprise Bank | 332 |
| 8 | JDCU | 191 |

ទិន្នន័យពីឆ្នាំ ២០២៤

# 05 ធនធានសម្រាប់អាជីវកម្មខ្នាតតូច

## ការអភិវឌ្ឍសេដ្ឋកិច្ចក្រុងឡូវែល៖

បុគ្គលិកនាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចក្រុងឡូវែល ធ្វើការនៅនាយកដ្ឋានផែនការ និងអភិវឌ្ឍន៍។ ពួកគាត់ជួយបង្កើតអាជីវកម្ម និងជួយរក្សាអាជីវកម្មឲ្យនៅគង់វង់។ ពួកគាត់សហការជាមួយភាគីពាក់ព័ន្ធ ដើម្បីថែរក្សាសង្កាត់ពាណិជ្ជកម្មឲ្យនៅរស់រវើក និងជួយគាំពារសហគមន៍ដែលមានភាពច្នៃប្រឌិត។ លេខទំនាក់ទំនង៖ dobizinlowell@lowellma.gov / 978-674-4252

## មជ្ឈមណ្ឌល CTI's E-Center៖

មជ្ឈមណ្ឌលសហគ្រិនភាព ផ្តល់ការបង្រៀនដល់អាជីវកម្មខ្នាតតូច និងកម្ចីពីស្ថាប័នឥណទាននៅមូលដ្ឋាន ដែលមានបទពិសោធន៍ ក្នុងការផ្តល់ប្រាក់កម្ចីដើម្បីជួយអាជីវកម្ម។ ពួកគាត់មានឧបករណ៍សំខាន់ចាំបាច់ និងការណែនាំដែលចាំបាច់ ដើម្បីចាប់ផ្តើមដំណើរសហគ្រាសរបស់អ្នក និងធានាការលូតលាស់ប្រាកដមួយ។ មជ្ឈមណ្ឌលនេះ អាចជួបគ្នាដោយផ្ទាល់ ឬតាមអនឡាញ ដើម្បីទទួលបានការណែនាំមួយទល់មួយ។ លេខទំនាក់ទំនង៖ avong@commteam.org / 978-654-5731

## សហគ្រិនសម្រាប់រាល់គ្នា ឬ EForAll៖

សហគ្រិនសម្រាប់គ្រប់គ្នា (ឬ EforAll) នេះជាអង្គការមិនរកប្រាក់កម្រៃថ្នាក់ជាតិ ដែលជួយអ្នកមានបំណងបើកអាជីវកម្ម ឲ្យជោគជ័យក្នុងការចាប់បើកមុខរបរ និងបន្តរីកចម្រើន។ អង្គការនេះផ្តល់ជាវគ្គបណ្តុះបណ្តាលស៊ីជម្រៅក្នុងរយៈពេលខ្លី, ផ្តល់ជាជំបូន្មាន និងជួយពង្រីកបណ្តាញអ្នកជំនួញ។ កម្មវិធីបណ្តុះបណ្តាល ធ្វើជាភាសាអង់គ្លេស និងអេស្ប៉ាញ។ លេខទំនាក់ទំនង៖ merrimackvalley@eforall.org / 1-833-336-7255 x7201

## សាជីវកម្មអភិវឌ្ឍន៍ហិរញ្ញវត្ថុឡូវែល (LDFC)៖

សាជីវកម្មនេះ ផ្តល់កម្ចីការប្រាក់ទាប ដើម្បីជួយជំរុញការអភិវឌ្ឍពាណិជ្ជកម្ម និងលំនៅឋាន ក្នុងទីក្រុងឡូវែល។ ដោយមានកិច្ចសហការគ្នាជាមួយ សាលាក្រុងឡូវែល និងធនាគារនៅមូលដ្ឋានឯទៀត សាជីវកម្ម LDFC ក៏មានផ្តល់កម្មវិធីថវិកាជំនួយសម្រាប់តំបន់ប្រជុំជនកណ្តាលក្រុង ដែលមានថវិកាកម្ចីដែលមានការប្រាក់ទាប សម្រាប់ជួយដល់ហាងលក់រាយថ្មីៗ និងភោជនីយដ្ឋាន ដែលមានទីតាំងក្នុងទីប្រជុំជនកណ្តាលក្រុង។ លេខទំនាក់ទំនង៖ allison@lowellplan.org / 978-459-9899

## ធនធានបន្ថែម៖

រដ្ឋបាលអាជីវកម្មខ្នាតតូច, សភាពាណិជ្ជកម្មមហាតំបន់ឡូវែល, MassSave, MassDevelopment, មេធាវីការពារសិទ្ធិពលរដ្ឋ, ការិយាល័យអភិវឌ្ឍន៍អាជីវកម្មរដ្ឋម៉ាសាឈូសេត, មជ្ឈមណ្ឌលសម្រាប់ស្ត្រី និងសហគ្រាស, សម្ព័ន្ធ Black Lowell Coalition។.